**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១៣.០១៨.០១១ ស្រ.ភ.៣.ម

*ថ្ងៃព្រហស្បតិ៍ ១១កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨*

# សេចក្ដីប្រកាសព័ត៌មាន

## សន្និសីទរួម ស្ដីពី «ត្រីវិស័យឆ្ពោះទៅកាន់ពិពិធកម្ម និងការផ្លាស់ប្ដូររចនាសម្ព័ន្ធសេដ្ឋកិច្ច ៖ ជំហានបន្ទាប់នៃការអភិវឌ្ឍកម្ពុជា»

នៅថ្ងៃព្រហស្បតិ៍ ១១កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាសហការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិរៀបចំសន្និសីទរួម ស្ដីពី «ត្រីវិស័យឆ្ពោះទៅកាន់ពិពិធកម្ម និងការផ្លាស់ប្ដូររចនាសម្ព័ន្ធសេដ្ឋកិច្ច ៖ ជំហានបន្ទាប់នៃការអភិវឌ្ឍកម្ពុជា» នៅសណ្ឋាគារ Raffles Hotel Le Royal ក្រោមអធិបតីភាព លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង លោកបណ្ឌិត Markus Rodlauer អនុប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។ សន្និសីទនេះ មានការអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការជាតិនិងអន្តរជាតិ មជ្ឈដ្ឋានសិក្សា គ្រឹះស្ថានស្រាវជ្រាវ គ្រឹះស្ថានធនាគារ និងវិស័យឯកជន សរុបប្រមាណ ២០០នាក់។

គោលបំណងនៃសន្និសីទនេះគឺ ដើម្បីផ្ដល់ជាវេទិកាសម្រាប់អ្នករៀបចំគោលនយោបាយនិងអ្នកជំនាញជាតិនិងអន្តរជាតិ បានជួបពិភាក្សាអំពីបញ្ហាប្រឈមចម្បងៗដែលត្រូវដោះស្រាយ ដើម្បីឈានទៅដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍ និងស្វែងរកដំណោះស្រាយគោលនយោបាយសម្រាប់កម្ពុជា។ អង្គសន្និសីទបានពិភាក្សាលើប្រធានបទចំនួន២ គឺ ៖ ១/- ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពប្រកួតប្រជែងនិងពិពិធកម្មដើម្បីប្រើប្រាស់សក្ដានុពលរបស់កម្ពុជា និង ២/- ការពិនិត្យមើលបទពិសោធន៍ដែលកម្ពុជាអាចទទួលយកពីអន្តរជាតិក្នុងដំណើរការវិវត្តផ្នែករចនាសម្ព័ន្ធនៃដំណាក់កាលថ្មីនៃការអភិវឌ្ឍ ដោយវាគ្មិនល្បីៗជាច្រើនរូបផងដែរ។

សន្និសីទនេះប្រព្រឹត្តទៅដោយជោគជ័យ និងផ្លែផ្កា ព្រមទាំងមានការចែករំលែកនូវបទពិសោធន៍និងគន្លឹះសំខាន់ៗដល់គ្រឹះស្ថានធនាគារ ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងផ្ដល់ជាធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំគោលនយោបាយប្រកបដោយភាពគ្រប់ជ្រុងជ្រោយ សំដៅរួមចំណែកធានាឱ្យបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

ធនាគារជាតិនៃកម្ពុជា និងមូលនិធិរូបិយវត្ថុអន្តរជាតិ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម វង្សី វិស្សុត រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តមបណ្ឌិត សុខ ស៊ីផាន់ណា នាយកគ្រប់គ្រងក្រុមហ៊ុន SokSiphana&Associates និងវាគ្មិនដទៃទៀត ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងសន្និសីទខាងលើ។

ទំនាក់ទំនង៖
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៥០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh